# ពិធីការសម្រាប់ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញ៖ ឧបសម្ព័ន្ធ E

## កាលបរិច្ឆេទចូលជាធរមាន៖ ម៉ោង 12:01 អធ្រាត្រថ្ងៃ ទី 6 ខែឧសភា ឆ្នាំ 2021

**បច្ចុប្បន្នភាពថ្មីៗ** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**5/5/2021:**

- ភាសាសម្រាប់ការសម្អាតត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីស្របទៅនឹងការណែនាំនៃការសម្អាតរបស់ CDC ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយដែរ។
- ភាសាសម្រាប់ការសុំច្បាប់ឈឺត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរច្បាប់ឈប់សម្រាកឈឺដែលទទួលបានប្រាក់ខែពីរដ្ឋ។

អត្រាករណី ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19 មានការថយចុះខ្លះ ហើយហាក់ដូចជាមានស្ថេរភាព ប៉ុន្តែជំងឺ COVID-19 នៅតែមានហានិភ័យ (risk) ខ្ពស់ចំពោះសហគមន៍ និងតម្រូវឲ្យប្រជាជន និងអាជីវកម្មទាំងអស់មានការប្រុងប្រយ័ត្ន និងកែប្រែប្រតិបត្តិការ និងសកម្មភាពដើម្បីកាត់បន្ថយហានិភ័យ (risk) នៃការរីករាលដាល។

ដោយសារខោនធី Los Angeles ចូលក្នុង "លំដាប់ថ្នាក់ពណ៌លឿង(Yellow Tier)" នៃក្របខ័ណ្ឌផែនការដើម្បីសេដ្ឋកិច្ចមានសុវត្ថិភាពជាងមុន (Blueprint for a Safer Economy) របស់រដ្ឋ ពិធីការនេះត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីលើកលែងការរឹតបន្តឹងដែលជាក់លាក់សម្រាប់សកម្មភាពក្នុងមូលដ្ឋានមួយចំនួន។ ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញគួរបន្តប្រតិបត្តិការប្រកបដោយការប្រុងប្រយ័ត្ន និងគោរពតាមល័ក្ខខ័ណ្ឌតម្រូវនៅក្នុងពិធីការនេះ ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19 ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles (LACDPH) កំពុងអនុវត្តតាមការណែនាំរបស់រដ្ឋ ដើម្បីជួយរក្សាឲ្យមជ្ឈមណ្ឌលលក់ទំនិញ ទីផ្សារ ក៏ដូចជាផ្សារណាត់ និងអាជីវកម្មលក់រាយនៅតាមហាងរបស់ពួកគេ បន្តបើកដំណើរការដោយមានការកែប្រែក្នុងអំឡុងពេលនៃជំងឺរាតត្បាតសកលនេះ។ សេចក្តីតម្រូវខាងក្រោមគឺជាក់លាក់សម្រាប់ទីតាំងនៅខាងក្នុង និងខាងក្រៅអគារ មជ្ឈមណ្ឌលលក់ទំនិញគោលដៅ ផ្សារលក់ទំនិញពីក្រុមហ៊ុន (outlet) និងផ្សារណាត់ (ជារួមហៅថា "មជ្ឈមណ្ឌលលក់ទំនិញ")។ ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញគួរតែប្រាប់ដល់អ្នកជួល រួមទាំងអ្នកជួលហាងលក់រាយ និងអ្នកលក់ទំនិញ នឹងពីពិធីការដែលអនុវត្តទៅលើប្រតិបត្តិការរបស់ពួកគេ។ អង្គភាពទាំងនោះ ("អ្នកជួល និងអ្នកលក់") ទទួលខុសត្រូវលើការអនុវត្តពិធីការ ប៉ុន្តែប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញ ត្រូវបានលើកទឹកចិត្តឲ្យទាមទារការអនុវត្តតាមពិធីការដោយអ្នកជួលរបស់ខ្លួន។ បន្ថែមលើល័ក្ខខ័ណ្ឌដែលបានដាក់ចុះដោយអភិបាលរដ្ឋទៅលើអាជីវកម្មលក់រាយជាក់លាក់ទាំងនេះ អាជីវកម្មប្រភេទទាំងនេះក៏ត្រូវគោរពតាមល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងបញ្ជីត្រួតពិនិត្យសម្រាប់ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញ (Checklist for Shopping Center Operators) នេះផងដែរ។

ចំនួនមនុស្សអតិបរមាដែលនៅក្នុងមជ្ឈមណ្ឌលលក់ទំនិញ ដូចបានកំណត់ខាងលើ ត្រូវបានដាក់កម្រិតត្រឹម 75% នៃចំនួនមនុស្សអតិបរមា ដើម្បីធានាការរក្សាគម្លាតរាងកាយ។ អាជីវកម្មក្នុងអគារដែលជាផ្នែកនៃផ្សារក្នុងអគារ ឬមជ្ឈមណ្ឌលលក់ទំនិញ ក៏ត្រូវបានកម្រិតត្រឹម 75% នៃចំនួនមនុស្សអតិបរមាផងដែរ។

កន្លែងអង្គុយខាងក្រៅអគារអចិន្ត្រៃយ៍និងថេរទាំងអស់ដែលបើកឲ្យសាធារណជនប្រើប្រាស់ ត្រូវតែមានបិទស្លាកសញ្ញានៅក្នុងកន្លែងដែលមើលឃើញច្បាស់នៅតាម ឬជិតកន្លែងអង្គុយអចិន្ត្រៃយ៍ដែលរំលឹកដល់អតិថិជនអំពីសេចក្តីតម្រូវឲ្យពាក់ម៉ាស់ អនុវត្តការរក្សាគំលាតរាងកាយនិងមិនត្រូវបរិភោគឬផឹកខណៈពេលស្ថិតនៅលើបរិវេណមជ្ឈមណ្ឌលលក់ទំនិញឡើយ។ ទីកន្លែងទូទៅដែលនៅខាងក្នុងអគារទាំងអស់ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលលក់ទំនិញ ឬផ្សារទំនើប អាចបើកឡើងវិញទៅតាមការកំណត់ចំនួនដែលមានការអនុញ្ញាតតម្រូវឲ្យមានទំហំទីតាំងគ្រប់គ្រាន់យ៉ាងហោចណាស់រក្សាចម្ងាយប្រាំមួយហ្វីត (6) រវាងសមាជិកដែលមិនមែនជាគ្រួសារ។ តុ និងកៅអីបណ្តោះអាសន្ន ឬអាចចល័តដែលនៅខាងក្រៅអគារទាំងអស់ដែលមិនស្ថិតនៅក្នុងទីកន្លែងបរិភោគខាងក្នុង ឬខាងក្រៅអគារ ដែលបានកំណត់ ស្ថិតនៅលើបរិវេណមជ្ឈមណ្ឌលលក់ទំនិញ អាចបើកឡើងវិញដោយរៀបចំតុ *ដែលមានចម្ងាយយ៉ាងតិច 6 ហ្វីតពីគ្នា ដោយវាស់កៅអីខាងក្រោយនៅតាមតុទល់នឹងកៅអីខាងក្រោយដែលមានតុជាប់ជិតគ្នានោះ ខណៈពេលអតិថិជនកំពុងអង្គុយ ហើយមិនអាចអង្គុយលើសពីបួននាក់នៅតាមតុបានទេ*។ សាធារណជន/ភ្ញៀវត្រូវតែបានរំលឹកថាពេលមិនអង្គុយនៅតាមកន្លែងបរិភោគដែលបានកំណត់ គឺមិនអនុញ្ញាតឲ្យមានការបរិភោគ ឬផឹក

នៅលើបរិវេណមជ្ឈមណ្ឌលលក់ទំនិញឡើយ។ សាធារណជន/ភ្ញៀវអាចបរិភោគ ឬផឹកនៅទីកន្លែងបរិភោគអាហារ ដែលបានកំណត់នៅខាងក្នុង និងក្រៅអគារប៉ុណ្ណោះ ដែលអនុលោមតាមពិធីការសម្រាប់ភោជនីយដ្ឋាន ឧបសម្ព័ន្ធ I ។ តុដែលបានកំណត់រៀបចំសម្រាប់ទីតាំងទទួលអាហារត្រូវតែមានចន្លោះពីគ្នា *យ៉ាងហោចណាស់ប្រាំមួយ (6) ហ្វីតពីគ្នា ដោយវាស់កៅអីខាងក្រោយនៅតាមតុទល់នឹងកៅអីខាងក្រោយដែលមានតុជាប់ជិតគ្នានោះ ខណៈពេលអតិថិជនបានអង្គុយដែរ។*

សកម្មភាពកម្សាន្តជាលក្ខណៈគ្រួសារដែលមានទីតាំងស្ថិតនៅក្នុងផ្សារទំនើប (ឧ. ការបោះប៉ូ ការជិះកង់ ឧបករណ៍បង្វិលដែលមានកុមារតែម្នាក់ឯង។ល។) អាចត្រូវបានអនុញ្ញាតឲ្យ បើកឡើងវិញដោយអនុលោមតាម[ពិធីសារសម្រាប់មជ្ឈ មណ្ឌលកម្សាន្តគ្រួសារ]របស់ DPH នៃខោនធី LA។

ហាងជួលទាំងអស់ គួរអនុវត្តតាមពិធីការ DPH សម្រាប់វិស័យដែលសមស្របក៏ដូចជាច្បាប់ និងបទប្បញ្ញត្តិក្នុងតំបន់ និងរបស់រដ្ឋជាធរមានទាំងអស់។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាននិងធនធានបន្ថែម ដូច្នេះ សូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំ សម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។

ពិធីការបន្ថែមទាក់ទងនឹងការធ្វើប្រតិបត្តិការមជ្ឈមណ្ឌលលក់ទំនិញ ក៏ត្រូវតែអនុវត្តតាមផងដែរ៖

- សេវាកម្មថែទាំផ្ទាល់ខ្លួន
- រោងភាពយន្ត
- មជ្ឈមណ្ឌលហាត់ប្រាណកន្លែងហាត់ប្រាណ។/
- ភោជនីយដ្ឋាន
- អាជីវកម្មលក់រាយ
- បារ

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក
(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយ
(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ
(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណៈជន
(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយ នៅពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**អាជីវកម្មទាំងអស់ដែលស្ថិតក្រោមពិធីការនេះ ត្រូវតែអនុវត្តវិធានការណ៍ជាធរមានទាំងអស់ ដែលមានរាយខាងក្រោមនេះ និងត្រូវត្រៀមខ្លួនពន្យល់ពីមូលហេតុក្នុងករណីដែលវិធានការណ៍ណាមួយមិន ត្រូវបានអនុវត្តដោយសារភាពមិនសមស្របសម្រាប់អាជីវកម្ម។**

**ឈ្មោះអាជីវកម្ម៖** ______________________

**អាសយដ្ឋានទីកន្លែង៖** ______________________

**ចំនួនមនុស្សអតិបរមា តាមច្បាប់សំណង់៖** ______________________

**ប្រហាក់ប្រហែលទំហំទីធ្លាគិតសរុបជាហ្វីតការ៉េ ដែលបើកដល់សាធារណៈជន៖** ______________________

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ អ្នកដែលមានបញ្ហាសុខភាពប្រចាំកាយ) ត្រូវបានកំណត់ការងារដែលអាចធ្វើការពីផ្ទះគ្រប់ពេលដែលអាចធ្វើបាន និងគួរពិភាក្សាអំពីក្តីកង្វល់នានាជាមួយអ្នកផ្តល់សេវាសុខភាព ឬសេវាកម្មសុខភាពការងាររបស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តបានសមស្របអំពីការត្រឡប់ទៅកន្លែងធ្វើការវិញ។
- ❑ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិកធ្វើការងារពីផ្ទះបាន។
- ❑ម្យ៉ាងវិញទៀត កាលវិភាគឆ្លាស់វេនគ្នា ឬប្តូរវេនគ្នាត្រូវបានអនុវត្តដើម្បីបង្កើនការរក្សាគំលាតរាងកាយឲ្យអតិបរមា។
- ❑ បុគ្គលិកទាំងអស់ត្រូវបានប្រាប់មិនឲ្យមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយបុគ្គលដែលមានជំងឺ COVID-19។ បុគ្គលិកយល់និងអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនិងការនៅដាច់ពីគេ បើសិនជាអាចអនុវត្តបាន។ គោលការណ៍សុំច្បាប់ឈប់សម្រាកនៅកន្លែងធ្វើការត្រូវបានពិនិត្យឡើងវិញ និងបានកែប្រែដើម្បីធានាថាបុគ្គលិកមិនត្រូវបានពិន័យនៅពេលពួកគេស្ថិតនៅផ្ទះដោយសារជំងឺ។
  - ព័ត៌មានអំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ ត្រូវបានផ្តល់ឲ្យបុគ្គលិក។ សូមមើលព័ត៌មានបន្ថែមស្តីពី កម្មវិធី រដ្ឋាភិបាលដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ឈប់សម្រាកដោយជំងឺCOVID-19បន្ថែមនៅឆ្នាំ 2021។
- ❑ ការត្រួតពិនិត្យការចូល ត្រូវបានធ្វើឡើងមុនពេលបុគ្គលិក អ្នកស្ម័គ្រចិត្ត បុគ្គលិកដឹកជញ្ជូន និងដៃគូសហការអាចចូលក្នុងកន្លែងធ្វើការ ដោយអនុលោមតាមការណែនាំអំពីការត្រួតពិនិត្យការចូលរបស់ DPH។ ការពិនិត្យតាមច្រកចូលត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងគ្រុនក្តៅ ឬរងារញាក់ ការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងលែងដឹងរសជាតិឬក្លិនថ្មីនិងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែកនិងឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬទេ។ ការពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់បន្ទាប់ពីបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
  - ការត្រួតពិនិត្យអវិជ្ជមាន (មិនមានបញ្ហា)។ បើសិនជាបុគ្គលគ្មានរោគសញ្ញា និងមិនមានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលគេបានស្គាល់ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ពួកគេអាចចូលធ្វើការសម្រាប់ថ្ងៃនោះបាន។
  - ការត្រួតពិនិត្យវិជ្ជមាន (មានបញ្ហា)៖
    - ប្រសិនបើបុគ្គលនោះមិនបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺ COVID-19[1]ពេញលេញ និងមានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលគេបានស្គាល់ក្នុងរយៈពេល 10ថ្ងៃចុងក្រោយ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ពីគេ ពួកគេមិនអាចចូល ឬធ្វើការនៅកន្លែងជាក់ស្តែងបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ពីគេនៅផ្ទះ។ ចូរផ្តល់ការណែនាំអំពីការនៅដាច់ពីគេដល់ពួកគេដែលអាចរកបាននៅ ph.lacounty.gov/covidquarantine ។
    - បើសិនជាបុគ្គលនោះកំពុងចេញរោគសញ្ញាណាមួយដែលបានកត់សម្គាល់ខាងលើ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ពួកគេមិនអាចចូល ឬធ្វើការនៅកន្លែងជាក់ស្តែងបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ដោយឡែកនៅផ្ទះ។ ចូរផ្តល់ឲ្យពួកគេនូវការណែនាំអំពីការនៅដាច់ដោយឡែកដែលអាចរកបាននៅ ph.lacounty.gov/covidisolation ។
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោងឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យដាក់ខ្លួនឲ្យនៅដាច់ពីគេភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬទេ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ សូមមើលការណែនាំសុខភាពសាធារណៈស្តីពី ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅក្នុងចំណោមមជ្ឈមណ្ឌលលក់ទំនិញ ឬនៅក្នុងអាជីវកម្មណាមួយដែលជាផ្នែកនៃមជ្ឈមណ្ឌលទិញទំនិញក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកត្រូវតែរាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821 ឬតាមអនឡាញនៅ http://www.redcap.link/covidreport។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាចង្កោម ដែលរួមមានដូចជាការផ្តល់ការណែនាំ

[1]បុគ្គលដែលត្រូវបានគេចាត់ទុកថាបានចាក់វ៉ាក់សាំងប្រឆាំងមេរោគCOVID-19គ្រប់ចំនួនគឺ គិតចាប់ពីពីរ(2)សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរ នៃប្រភេទវ៉ាក់សាំងពីរដូស (រួមមានPfizer -BioNTech ឬ Moderna) ឬ ពីរ(2)សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃ ប្រភេទដូសតែមួយដងរួចរាល់ហើយ (រួមមាន Johnson and Johnson [J&J]/Janssen) ។

និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ ត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាចង្កោមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។ នាយកដ្ឋានសុខភាពសាធារណៈនឹងត្រូវការការសហការភ្លាមៗពីទីកន្លែង ដើម្បីកំណត់ថាតើចង្កោមករណីនេះបង្កើតជាការផ្ទុះជំងឺ COVID-19 ឬទេ។

- ❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃបានទទួលម៉ាស់សមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រម៉ាស់ជំងឺ COVID-19 របស់ LAC DPH នៅ http://publichealth.lacounty.gov/acd/ ncorona2019/masks។ ម៉ាស់គឺត្រូវពាក់ដោយបុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់ម៉ាស់ ត្រូវតែប្រើសន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាលក្ខខណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹតតឹងនៅខាងក្រោមចង្កា។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវគឺមិនត្រូវប្រើឡើយ។ បុគ្គលិកទាំងអស់ត្រូវតែពាក់ម៉ាស់នៅគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជនដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ករណីលើកលែងដែលមានសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូចដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់របស់បុគ្គលិក ពេលនេះត្រូវបានដកចេញក្នុងអំឡុងរយៈពេលមានប្រសិទ្ធភាពនៃសេចក្តីបង្គាប់បណ្តោះអាសន្ននេះ រហូតដល់មានការជូនដំណឹងសារជាថ្មី។
- ❑ ដើម្បីប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានហាមឃាត់មិនឲ្យបរិភោគ ឬផឹកលើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួនទិញរក្សាគម្លាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក គួរតែធ្វើនៅខាងក្រៅអគារនិងឆ្ងាយពីអ្នកដទៃ បើសិនជាអាចធ្វើបាន។ ការបរិភោគ ឬការផឹកនៅបន្ទប់តូចឬស្ថានីយការងារគឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក បើសិនជាការបរិភោគនៅបន្ទប់តូច ឬស្ថានីយការងារផ្តល់ជូនគំលាតកាន់តែធំនិងរបាំងរវាងបុគ្គលិក។ ការចម្លងជំងឺ COVID-19 ទំនងជាកើតឡើងនៅពេលដែលបុគ្គលិកមានវត្តមានជាមួយគ្នានៅពេលដែលមិនពាក់ម៉ាស់។
- ❑ ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគំលាតរវាងបុគ្គលិក ត្រូវបានបង្កើនអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានាដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយ៖
  - ○ បិទផ្សាយស្លាកសញ្ញាអំពីចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឲ្យមានការរក្សាគំលាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក និង
  - ○ ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក ព្រមទាំង
  - ○ ដាក់តុឃ្លាតពីគ្នាយ៉ាងតិចបំផុតប្រាំមួយហ្វីត និងធានាបាននូវគំលាតប្រាំមួយហ្វីតរវាងកន្លែងអង្គុយ ដោយដកកៅអី ឬបិទបង់ស្ទិកលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋដើម្បីធានាបាននូវការរក្សាគំលាត និងរៀបចំកន្លែងអង្គុយតាមរបៀបដែលអាចបន្ថយការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឲ្យការកាត់បន្ថយចំនួនមនុស្សនិងការរក្សាគំលាតរាងកាយឡើយ។
- ❑ នៅកន្លែងដែលអាចធ្វើបាន ទីកន្លែងសម្រាកខាងក្រៅអគារត្រូវបានបង្កើតឡើង និងត្រូវបានបំពាក់ជាមួយនឹងគម្របម្លប់ និងកន្លែងអង្គុយដែលអនុញ្ញាតឲ្យបុគ្គលិករក្សាគំលាតរាងកាយ 6 ហ្វីតពីអ្នកដទៃនៅគ្រប់ពេលវេលា។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យលាងសម្អាត ឬផ្លាស់ប្តូរម៉ាស់របស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ ស្ថានីយការងារទាំងអស់ត្រូវបានបំបែកពីគ្នាយ៉ាងតិចប្រាំមួយហ្វីត។

បន្ទប់សម្រាក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគតាមភាពញឹកញាប់ដូចពិពណ៌នាខាងក្រោម ប៉ុន្តែមិនតិចជាងម្តងក្នុងមួយថ្ងៃទេទៅតាមកាលវិភាគដូចខាងក្រោម៖

- ○ បន្ទប់សម្រាក ____________________
- ○ បន្ទប់ទឹក ____________________
- ○ ផ្សេងទៀត ____________________

- ❑ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីប្រាក់ឈ្នួល និងម៉ោងធ្វើការ ការសម្រាកត្រូវបានកំណត់ដាច់ៗពីគ្នាដើម្បីប្រាកដថាបុគ្គលិកអាចរក្សាគំលាតប្រាំមួយ (6) ហ្វីតពីគ្នានៅក្នុងបន្ទប់សម្រាកនៅគ្រប់ពេលវេលា។
- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោម៖

____________________________________________

- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាង

ហួសសុពលភាព-មិនមានប្រសិទ្ធភាព

ក្រោម៖

______________________________________________________________

- ❑ បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកឲ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។
- ❑ កម្មករនីមួយៗត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងលំហធ្វើការដែលបានកំណត់។ នៅគ្រប់ពេលដែលអាចធ្វើបាន ការប្រើប្រាស់វត្ថុដែលបានប៉ះពាល់ (ឧ. ទូរស័ព្ទ ថេប្លិត កុំព្យូទ័រយួរដៃ តុ ប៊ិច ។ល។) ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ❑ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះក្រៅពីគោលការណ៍ដែលទាក់ទងនឹងល័ក្ខខណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។
- ❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

- ❑ វិធានស្តីពីចំនួនមនុស្សអតិបរមាសម្រាប់មជ្ឈមណ្ឌលលក់ទំនិញ (ខាងក្នុងអគារ និងខាងក្រៅអគារ) និងសម្រាប់អាជីវកម្មលក់រាយដែលជាផ្នែកនៃមជ្ឈមណ្ឌលលក់ទំនិញ មិនអាចមានចំនួនមនុស្សលើសពី 75% នៃចំនួនមនុស្សអតិបរមាឡើយ ក្នុងករណីដែលការរក្សាគំលាតរាងកាយ 6 ហ្វីតក្នុងចំណោមអតិថិជននិងបុគ្គលិកអាចរក្សាបានជានិច្ច។ នៅពេលដែលអាចធ្វើបាន ការចតយានយន្តត្រូវបានដាក់កម្រិតដើម្បីអនុវត្តការដាក់កម្រិតលើចំនួនផ្ទុកអតិបរមាបន្ថែមទៀត។
- ❑ ហាងអ្នកជួលដែលមានច្រកចូលពីខាងក្រៅ ដែលជាធម្មតាអាចប្រើប្រាស់បានសម្រាប់សាធារណជនពីផ្នែកខាងក្រៅនៃផ្សារ ឬមជ្ឈមណ្ឌលលក់ទំនិញ អាចបន្តប្រតិបត្តិការដែលបានកែប្រែបច្ចុប្បន្នរបស់ខ្លួនដោយអនុលោមតាមពិធីការ DPH ជាធរមានដោយមានចំនួនមនុស្សច្រើនបំផុត 75%។ មជ្ឈមណ្ឌលលក់ទំនិញចំបង ដូចជាផ្សារណាត់ ត្រូវធ្វើឲ្យប្រាកដថាអ្នកលក់រៀបចំតុ ធ័ត្រ និងការដាក់បង្ហាញផ្សេងទៀតដោយយោងតាមសេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយដែលសមស្រប ឬត្រូវប្រាកដថារបាំងដែលមិនជ្រាបត្រូវបានដំឡើង។
  - ○ ចំនួនអតិថិជនអតិបរមានៅក្នុងទីកន្លែងត្រូវបានដាក់កម្រិតត្រឹម៖ ______________________
- ❑ ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញ ត្រូវតែត្រួតពិនិត្យការចេញចូលរបស់អតិថិជនយ៉ាងតឹងរ៉ឹង និងជាបន្តបន្ទាប់នៅច្រកចូលដើម្បីតាមដានចំនួនមនុស្ស និងប្រាកដថា អាជីវកម្មកំពុងអនុលោមតាមការដាក់កម្រិតចំនួនមនុស្សខាងក្នុងអគារនាពេលបច្ចុប្បន្នរបស់ពួកគេ។ អ្នកលក់រាយដែលកំពុងធ្វើការត្រួតពិនិត្យមិនបានដិតដល់ ឬមិនធ្វើការត្រួតពិនិត្យ ឬមើលទៅដូចជាផ្ទុកចំនួនមនុស្សលើសកំណត់ អាស្រ័យលើការសម្រេចចិត្តរបស់មន្ត្រីអធិការកិច្ចសុខភាពសាធារណៈ គឺអាចត្រូវបិទទ្វារជាបណ្តោះអាសន្នរហូតដល់បញ្ហាទាំងនេះត្រូវបានកែតម្រូវ ដូចបានកំណត់ដោយមន្ត្រីអធិការកិច្ចសុខភាពសាធារណៈនៅនឹងកន្លែង។ នៅពេលដែលអាចធ្វើបាន ចូរផ្តល់ច្រកចូលដែលបានកំណត់ច្បាស់តែមួយ និងច្រកចេញដាច់ដោយឡែកដើម្បីជួយរក្សាគំលាតរាងកាយ។
- ❑ ត្រៀមរៀបចំឲ្យអតិថិជនតម្រង់ជួរនៅខាងក្រៅ ខណៈដែលនៅតែអនុវត្តការរក្សាគំលាតរាងកាយ រាប់បញ្ចូលទាំងការប្រើប្រាស់តម្រុយជារូបភាព។ បើសិនជាចាំបាច់ បុគ្គលិកម្នាក់ (ឬច្រើននាក់បើសិនជាមានច្រកចូលច្រើនជាងមួយ) ដែលពាក់ ម៉ាស់សមស្រប អាចត្រូវបានដាក់ឲ្យប្រចាំការនៅជិតទ្វារ ប៉ុន្តែមានគំលាតយ៉ាងតិច 6 ហ្វីតពីអតិថិជនដែលដើរកាត់ដើម្បីតាមដានចំនួនអតិថិជន និងដើម្បីណែនាំឲ្យអតិថិជនតម្រង់ជួរដោយឃ្លាតពីគ្នាប្រាំមួយហ្វីតនៅខាងក្រៅច្រកចូល បើសិនជាអាជីវកម្ម ឬមជ្ឈមណ្ឌលលក់ទំនិញបានឈានដល់ដែនកំណត់ចំនួនអតិថិជនរបស់ខ្លួន។
- ❑ បើអាចអនុវត្តបាន បុគ្គលិកសន្តិសុខនៅទីកន្លែងត្រូវរំលឹកនិងលើកទឹកចិត្តអតិថិជននិងសាធារណជនយ៉ាងសកម្មឲ្យអនុវត្តតាមស្តង់ដារនៃការរក្សាគំលាតរាងកាយ និងរំលឹកដល់អតិថិជននិងភ្ញៀវថាការបរិភោគ និងការផឹកនៅនឹងកន្លែងគឺមិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែទីកន្លែងបរិភោគអាហារខាងក្រៅអគារដែលបានកំណត់។
- ❑ វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយយ៉ាងតិចប្រាំមួយ (6) ហ្វីតត្រូវបានអនុវត្តដើម្បីធានា បាននូវការរក្សាគំលាតរាងកាយរវាងបុគ្គលិក និងអតិថិជននៅគ្រប់ទីតាំងមជ្ឈមណ្ឌលលក់ទំនិញទាំងអស់។ នេះអាចរាប់បញ្ចូលការប្រើប្រាស់ការបែងចែកជាក់ស្តែង ឬតម្រុយជារូបភាព (ឧ. ការសម្គាល់លើកម្រាលឥដ្ឋ បង់ស្អិតមានពណ៌ ឬសញ្ញាដើម្បីចង្អុលបង្ហាញពីកន្លែងដែលបុគ្គលិក និងអតិថិជនគួរឈរ)។
- ❑ អភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រចរាចរណ៍ថ្មើរជើងដែលមានការគ្រប់គ្រង និងការគ្រប់គ្រងហ្វូងមនុស្ស ដែលអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយយ៉ាងតិចប្រាំមួយហ្វីតរវាងអតិថិជន។ នេះអាចរាប់បញ្ចូលការតម្រូវឲ្យធ្វើចរាចរណ៍ថ្មើរជើងតែមួយទិស និងការដឹកនាំអតិថិជនដោយប្រើតម្រុយរូបភាព គ្រឿងសម្គាល់ពិត និងស្លាកសញ្ញា។
- ❑ ផ្តល់ជូនច្រកចូល និងច្រកចេញដាច់ដោយឡែកដែលបានកំណត់យ៉ាងច្បាស់ បើសិនជាអាចធ្វើបាននិងសមស្រប សម្រាប់ទីកន្លែង ដើម្បីជួយរក្សាគំលាតរាងកាយនិងជំនួយការគ្រប់គ្រងហ្វូងមនុស្ស។ នៅគ្រប់ពេលដែលអាចធ្វើបាន

គេគួរទុកទ្វារឲ្យចំហ បើសិនជាវាមិនបិទបើកដោយស្វ័យប្រវត្តិ។ ធ្វើការជាមួយហាងអ្នកជួលដើម្បីបង្កើតប្រព័ន្ធតម្រង់ជួរសម្រាប់អតិថិជននៅខាងក្រៅហាងនីមួយៗ ខណៈពេលនៅតែរក្សាគំលាតរាងកាយ បើសិនជាចាំបាច់។

- ❑ ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញ អ្នកជួលដើម្បីលក់រាយ និងអ្នកលក់គួរធ្វើការសហការដើម្បីបង្កើតប្រព័ន្ធតម្រង់ជួរចូលហាង ដែលមិនរំខានដល់ចរាចរណ៍ថ្មើរជើង ឬល្មើសសេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយ។ ពិចារណានិងលើកទឹកចិត្តឲ្យមានច្រកចូលផ្សេងទៅកាន់អគារអ្នកជួលលក់រាយ រួមទាំងគោលការណ៍ណែនាំអំពីការកក់បែបឌីជីថលសម្រាប់ការចូល និងការបញ្ជាទិញជាមុន។
- ❑ រទេះអ្នកលក់ ឬម៉ាស៊ីនលក់ (kiosks) គួរត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការនៅក្នុងរបៀង ឬកន្លែងដើរនៃមជ្ឈមណ្ឌលលក់ទំនិញប៉ុណ្ណោះ បើសិនជាវាមិនរំខានដល់វិធានការណ៍ស្តីពីចរាចរណ៍ថ្មើរជើងដែលបានធ្វើបច្ចុប្បន្នភាព ឬប៉ះពាល់ដល់សេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយ។ នៅពេលចាំបាច់ ធ្វើការរៀបចំរទេះ អ្នកលក់ ឬម៉ាស៊ីនលក់ឡើងវិញដើម្បីប្រាកដថាការតម្រង់ជួរ មិនប៉ះពាល់ដល់សេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយ។
- ❑ មជ្ឈមណ្ឌលលក់ទំនិញចំហ ដូចជាផ្សារណាត់ គួរធ្វើឲ្យប្រាកដថាអ្នកលក់រៀបចំតុ តង់ និងការដាក់បង្ហាញផ្សេងទៀតដោយយោងតាមសេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយសមស្រប ឬធ្វើឲ្យប្រាកដថារបាំងដែលមិនជ្រាបត្រូវបានដំឡើង។
- ❑ ប្រតិបត្តិករមជ្ឈមណ្ឌលលក់ទំនិញ អ្នកជួលហាងលក់រាយ និងអ្នកលក់គួរសហការដើម្បីបង្កើតកម្មវិធីប្រតិបត្តិការមជ្ឈមណ្ឌលទិញទំនិញ ដែលអនុញ្ញាតឲ្យហាងជួលធ្វើប្រតិបត្តិការដោយសុវត្ថិភាពនៅខាងក្នុងនិងខាងក្រៅមជ្ឈមណ្ឌលលក់ទំនិញ និងដើម្បីធានាបាននូវការអនុលោមតាមពិធីការ DPH ជាធរមាន ទាំងអស់ក៏ដូចជាច្បាប់និងបទប្បញ្ញត្តិក្នុងតំបន់ និងរបស់រដ្ឋ។
- ❑ ទីកន្លែងទូទៅដែលស្ថិតនៅក្នុងផ្សារទំនើប ឬមជ្ឈមណ្ឌលលក់ទំនិញខាងក្នុងអគារអាចបើកឡើងវិញដោយបន្ថយទៅតាមចំនួនសមស្របដើម្បីអនុញ្ញាតឲ្យមានការរក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតរវាងសមាជិកដែលមិនមែនគ្រួសារ។
- ❑ ការកម្សាន្តបន្តផ្ទាល់នៅខាងក្នុងអគារមិនត្រូវបានអនុញ្ញាតទេ។ ការកម្សាន្តបន្តផ្ទាល់នៅខាងក្រៅត្រូវតែធ្វើតាមពិធីការសម្រាប់ភោជនីយដ្ឋាន ឬពិធីបន្តសម្រាប់ព្រឹត្តិការណ៍ផ្សាយផ្ទាល់ខាងក្រៅឧបសម្ព័ន្ធទី Z ដែលអាចអនុវត្តទៅបាន។
- ❑ តុ និងកៅអីបណ្តោះអាសន្ន ឬអាចចល័តបានទាំងអស់ដែលស្ថិតនៅខាងក្នុងនៃបរិវេណមជ្ឈមណ្ឌលលក់ទំនិញត្រូវតែយកចេញ ឬបិទកុំឲ្យមានការប្រើប្រាស់ជាសាធារណៈ។ សាធារណជន/ភ្ញៀវត្រូវតែបានរំលឹកថាមិនអនុញ្ញាតឲ្យមានការបរិភោគ ឬផឹកនៅលើបរិវេណមជ្ឈមណ្ឌលលក់ទំនិញ លើកលែងតែទីកន្លែងបរិភោគអាហារដែលបានកំណត់។
- ❑ សេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយត្រូវតែអនុវត្តនៅកន្លែងលើកឥវ៉ាន់ (loading bay) ហើយហត្ថលេខាដោយមិនបាច់ប៉ះត្រូវបានអនុវត្តសម្រាប់ការដឹកជញ្ជូន។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ❑ ប្រព័ន្ធ HVAC គឺស្ថិតក្នុងសភាពដំណើរការល្អធម្មតា ដល់កម្រិតជាអតិបរមា ដែលអាចធ្វើឲ្យខ្យល់ចេញចូលត្រូវបានបង្កើនឡើង។ ខ្យល់ចេញចូលដែលមានប្រសិទ្ធភាព គឺជាវិធីដ៏សំខាន់បំផុតមួយដើម្បីគ្រប់គ្រងការចម្លងតាមអ៊ែរ៉ូសូល (aerosol) តូចៗ។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងការិយាល័យ និងទីកន្លែងផ្សេងៗទៀត។ មើល[ការណែនាំបណ្តោះអាសន្នរបស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ California សម្រាប់ការបញ្ចេញបញ្ចូលខ្យល់ ការច្រោះ និងគុណភាពខ្យល់នៅក្នុងបរិយាកាសខាងក្នុងអគារ]សម្រាប់ព័ត៌មាន លម្អិត។ សូមកត់សម្គាល់៖ ការកែលម្អខ្យល់ចេញចូល និងការកែលម្អគុណភាពខ្យល់ខាងក្នុងអគារផ្សេងៗទៀត គឺជាការបំពេញបន្ថែម និងមិនមែនជាការជំនួសឲ្យការការពារដែលចាំបាច់ ដូចជាការពាក់ម៉ាស់ (លើកលែងនៅក្នុងបរិយាកាសដែលមាន ហានិភ័យខ្ពស់ ដែលតម្រូវឲ្យមានការការពារផ្លូវដង្ហើមសមស្រប) ការរក្សាគំលាតយ៉ាងតិចប្រាំមួយហ្វីតពីគ្នា ការលាងដៃឲ្យបានញឹកញាប់ និងការដាក់កម្រិតសកម្មភាពដែលនាំមនុស្សមកពីគ្រួសារខុសៗគ្នាឲ្យមកជួបជុំគ្នា។
- ❑ អតិថិជនដែលមកដល់អាជីវកម្មត្រូវបានរំលឹកឲ្យពាក់ម៉ាស់នៅគ្រប់ពេលវេលា ខណៈពេលនៅក្នុងមជ្ឈមណ្ឌលលក់ទំនិញ ឬលើបរិវេណមជ្ឈមណ្ឌលលក់ទំនិញ លើកលែងតែខណៈពេលបរិភោគ/ផឹកនៅកន្លែងបរិភោគដែលបានកំណត់។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ បុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់ម៉ាស់ដោយអ្នក ផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួន ត្រូវតែពាក់សន្ទះបាំងមុខដែលមានក្រណាត់រឹបពីតែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាលក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់ដែលមានទម្រង់រឹបខាងក្រោមចង្កា។ មិនត្រូវប្រើម៉ាស់ដែលមានវ៉ាល់មួយផ្លូវឡើយ។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិកអ្នកនិងភ្ញៀវផ្សេងទៀតគួរផ្តល់ម៉ាស់ដល់ភ្ញៀវដែលមកដល់ដោយមិនមានម៉ាស់។
- ❑ ការពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចចូលក្នុងទីកន្លែង។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម គ្រុនក្តៅ គ្រុនរងានិងថាតើបុគ្គលនោះកំពុងស្ថិតក្រោម

សេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬទេ។ ការត្រួតពិនិត្យទាំងនេះ អាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងទៀតដូចជាប្រព័ន្ធចុះឈ្មោះតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែង។

- ការត្រួតពិនិត្យអវិជ្ជមាន (មិនមានបញ្ហា)។ បើសិនជាបុគ្គលគ្មានរោគសញ្ញានិងមិនមានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលគេបានស្គាល់ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ពួកគេអាចចូលសម្រាប់ថ្ងៃនោះបាន។
- ការត្រួតពិនិត្យវិជ្ជមាន (មានបញ្ហា)៖
  - បើសិនជាបុគ្គលរូបនោះមានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលគេបានស្គាល់ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ពីគេ ពួកគេមិនអាចចូលនិងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ពីគេ។ ចូរផ្តល់ការណែនាំអំពីការនៅដាច់ពីគេដល់ពួកគេដែលអាចរកបាននៅ ph.lacounty.gov/covidquarantine ។
  - បើសិនជាបុគ្គលរូបនោះកំពុងចេញរោគសញ្ញាណាមួយដែលបានកត់សម្គាល់ខាងលើ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ពួកគេមិនអាចចូលនិងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ដោយឡែកនៅផ្ទះ។ ចូរផ្តល់ឲ្យពួកគេនូវការណែនាំអំពីការនៅដាច់ដោយឡែកដែលអាចរកបាននៅ ph.lacounty.gov/covidisolation ។

❑ អតិថិជនដែលមកដល់អាជីវកម្មជាមួយក្មេងៗ ត្រូវតែប្រាកដថាកូនរបស់ពួកគេស្ថិតនៅជិតឪពុកម្តាយ ចៀសវាងការប៉ះអ្នកដទៃ ឬវត្ថុណាមួយដែលមិនមែនជារបស់ពួកគេ និងត្រូវពាក់ម៉ាស់បើសិនជាវ័យអាចពាក់។

❑ ប្រព័ន្ធបង់ប្រាក់ដោយមិនបាច់ប៉ះ គឺមានសម្រាប់ឲ្យប្រើ ឬបើមិនអាចធ្វើបាន ប្រព័ន្ធបង់ប្រាក់ត្រូវបានធ្វើអនាម័យយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ ពិពណ៌នា៖

________________________________________________________________

❑ ទីកន្លែងទូទៅ និងទីកន្លែងដែលមានចរាចរណ៍ខ្ពស់ ក៏ដូចជាវត្ថុដែលបានប៉ះពាល់ញឹកញាប់ (ឧ. បង្កាន់ដៃ ផ្នែកបញ្ជានៃជណ្តើរយន្ត ដៃទ្វារ ឬដៃកាន់ ម៉ាស៊ីនអានកាតឥណទាន ប៊ូតុងជណ្តើរយន្ត បង្កាន់ដៃជណ្តើរយន្តដើង ។ល។) ត្រូវបានសម្លាប់មេរោគយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃក្នុងអំឡុងម៉ោងធ្វើការ ដោយប្រើផលិតផលសម្លាប់មេរោគដែលបានអនុម័តដោយ EPA ដោយអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតសម្រាប់ការប្រើប្រាស់។

❑ ទីកន្លែងការងារនិងអគារទាំងមូលត្រូវបានសម្អាតយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ហើយបន្ទប់ទឹក និងតំបន់/វត្ថុដែលបានប៉ះញឹកញាប់ត្រូវបានសម្អាតញឹកញាប់ជាងនេះ ប្រសិនបើបានកំណត់ជាចាំបាច់។ ម៉ោងនៃមជ្ឈមណ្ឌលលក់ទំនិញត្រូវបានកែសម្រួលដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការសម្អាតស៊ីជម្រៅជាប្រចាំ និងការដាក់ស្តុកផលិតផល។

❑ បន្ទប់ទឹកសាធារណៈដែលនៅខាងក្រៅត្រូវបានត្រួតពិនិត្យជាប្រចាំ និងសម្អាតនិងសម្លាប់មេរោគយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ឬញឹកញាប់តាមដែលបានកំណត់ថាចាំបាច់ ដោយប្រើផលិតផលសម្លាប់មេរោគដែលបានអនុម័តដោយ EPA ដោយអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតសម្រាប់ការប្រើប្រាស់។

❑ ទឹកបាញ់សម្រាប់សាធារណៈផឹកត្រូវបានបិទ និងមានស្លាកសញ្ញាជម្រាបជូនអតិថិជនថាពួកគេមិនអាចប្រើវាបានទេ។

❑ បន្ទប់ទឹកបុគ្គលិកមិនអាចឲ្យអតិថិជនប្រើបានទេ។

❑ អតិថិជនអាចប្រើប្រាស់ផលិតផលអនាម័យសមស្រប រួមមានទឹកអនាម័យលាងដៃ ក្រដាសជូតមាត់និង ធុងសម្រាម។

❑ ទីកន្លែងបរិភោគរបស់អាហារដ្ឋានរបស់ផ្សារក្នុងអគារ ឬមជ្ឈមណ្ឌលលក់ទំនិញ អាចបើកដំណើរការជាមួយចំនួនមនុស្សអតិបរមា 50% នៃចំនួនមនុស្សតាមច្បាប់សំណង់ ឬច្បាប់អគ្គិភ័យជាធរមាន។ ទីកន្លែងបរិភោគខាងក្នុង និងខាងក្រៅអគារទាំងអស់ត្រូវតែអនុលោមតាមពិធីការសម្រាប់ភោជនីយដ្ឋានរបស់ DPH ខោនធី Los Angeles៖ ឧបសម្ព័ន្ធ I រួមទាំងការរៀបចំកន្លែងអង្គុយសម្រាប់បរិភោគអាហារនៅខាងក្នុងនិងខាងក្រៅអគារ។ សាធារណជនមិនអាចបរិភោគម្ហូបអាហារ ឬភេសជ្ជៈនៅកន្លែងណាមួយនៅលើបរិវេណផ្សារ ឬមជ្ឈមណ្ឌលលក់ទំនិញបានឡើយ លើកលែងតែទីកន្លែងបរិភោគអាហារដែលបានកំណត់។

❑ ស្រេចចិត្ត - ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត (ឧ. ការផ្តល់ម៉ោងសម្រាប់តែជនចាស់ជរា ការលើកទឹកចិត្តឲ្យធ្វើការបញ្ជាទិញតាមអនឡាញ/ការមកយកការបញ្ជាទិញ ផ្តល់ការលើកទឹកចិត្តសម្រាប់ការលក់នៅម៉ោងដែលមិនរវល់ខ្លាំង)៖

________________________________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណៈជន

❑ ច្បាប់ចម្លងនៃពិធីការនេះ ឬវិញ្ញាបនបត្របញ្ជាក់ការអនុវត្តតាមវិធានសុវត្ថិភាពជំងឺ COVID-19 ខោនធី Los Angeles របស់ទីផ្សារ ត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងកន្លែង។ សម្រាប់ព័ត៌មានបន្ថែមឬដើម្បីបំពេញកម្មវិធីវិញ្ញាបនបត្របញ្ជាក់ដោយខ្លួនឯងពីការអនុវត្តតាមវិធានសុវត្ថិភាពជំងឺ COVID-19 សូមចូលទៅកាន់ http://publichealth.lacounty.gov/eh/covid19cert.htm។ ទីកន្លែងត្រូវតែរក្សាច្បាប់ចម្លងនៃពិធីការនេះនៅនឹងកន្លែងសម្រាប់ការត្រួតពិនិត្យឡើងវិញទៅតាមការស្នើសុំ។

- ❑ ស្លាកសញ្ញានៅផ្សារទំនើប ផ្សារណាត់ និងច្រកលក់ផ្សេងៗទៀតដែលរំលឹកឲ្យអតិថិជនរក្សាគំលាតរាងកាយប្រាំមួយហ្វីត ការចាំបាច់ដែលត្រូវពាក់ម៉ាស់នៅគ្រប់ពេលវេលា សារៈសំខាន់នៃការលាងដៃជាប្រចាំ និងការចាំបាច់ដែលត្រូវស្ថិតនៅផ្ទះ បើសិនជាពួកគេមានអារម្មណ៍ថាឈឺ ឬមានរោគសញ្ញានៃជំងឺ COVID-19។ មើលគេហទំព័រការណែនាំជំងឺ COVID-19 របស់ DPH ក្នុងខោនធីសម្រាប់ធនធានបន្ថែម និងស្លាកសញ្ញាគំរូដែលអាជីវកម្មអាចប្រើប្រាស់បាន។
- ❑ ស្លាកសញ្ញានៅក្នុងមជ្ឈមណ្ឌលលក់ទំនិញទាំងមូលរំលឹកដល់អតិថិជនថា មិនអនុញ្ញាតឲ្យមានការបរិភោគ ឬការផឹកនៅខាងក្នុងមជ្ឈមណ្ឌលទិញទំនិញឡើយ លើកលែងតែទីកន្លែងបរិភោគខាងក្នុងអគារដែលបានកំណត់នៅអាហារដ្ឋាននិងនៅក្នុងទីកន្លែងបរិភោគខាងក្រៅអគារដែលបានកំណត់នានា។
- ❑ ស្លាកសញ្ញានៅទូទាំងមជ្ឈមណ្ឌលលក់ទំនិញចង្អុលបង្ហាញដល់អតិថិជនពីទីកន្លែងដើម្បីស្វែងរកឧបករណ៍បាញ់ទឹកអនាម័យលាងដៃដែលជិតបំផុត។
- ❑ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងបើកហាង ការតម្រូវឲ្យប្រើម៉ាស់ ចំនួនអតិថិជនមានកំណត់ គោលការណ៍ផ្សេងៗដែលទាក់ទងនឹងការបញ្ជាទិញជាមុន ការបង់ប្រាក់ជាមុន ការមកយកទំនិញនិង/ឬការដឹកជញ្ជូន និងបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ បើសិនជាសមស្រប ម៉ោងទិញឥវ៉ាន់ដាច់ដោយឡែកសម្រាប់ប្រជាជនងាយរងគ្រោះ ដូចជាមនុស្សចាស់ជរា និងអ្នកដែលងាយរងគ្រោះតាមបែបវេជ្ជសាស្ត្រត្រូវបានចាប់ផ្តើម យកល្អបន្ទាប់ពីសម្អាតរួច។
- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់អតិថិជន ត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជនដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម៖** ____________________ **លេខទូរស័ព្ទ៖** ____________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ____________________